ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

MINISTRY OF ECONOMY AND FINANCE

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ: ០០៥.....សហវ.អពដ

រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ មករា ឆ្នាំ ២០០៦

# សេចក្តីជូនដំណឹង

## ស្តីពី

## ការដាក់ឱ្យប្រើប្រាស់ លិខិតប្រកាសពន្ធលើប្រាក់ចំណេញគំរូថ្មី

អនុលោមតាមព្រះរាជក្រមលេខ នស/រកម/០៧០២/០១១ ចុះថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០០២ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មានកិត្តិយសសូមជូនដំណឹងដល់លោក-លោកស្រី អភិបាល បណ្ណាធិការ ឬកម្មសិទ្ធករ សហគ្រាស ដែលស្ថិតក្រោមការគ្រប់គ្រងប្រមូលពន្ធតាមរបបប្រព័ន្ធស្វ័យប្រកាស សូមមេត្តាជ្រាបថា ចាប់ពីដំណាច់ការិយបរិច្ឆេទឆ្នាំ២០០៥ តទៅ ការដាក់លិខិតប្រកាសពន្ធលើប្រាក់ចំណេញប្រចាំឆ្នាំត្រូវអនុវត្តតាមគំរូថ្មីដែលមានខ្លឹមសារសង្ខេបដូចតទៅ :

១- **ទំព័រទី១** : ស្តីពីពត៌មានទូទៅរបស់សហគ្រាសរួមមាន: ឈ្មោះសហគ្រាស អាស័យដ្ឋាន ការិយបរិច្ឆេទ សារពើពន្ធ សកម្មភាពអាជីវកម្ម ឈ្មោះអភិបាល-បណ្ណាធិការ ឬកម្មសិទ្ធករ ប្រព័ន្ធគណនេយ្យ ទ្រង់ទ្រាយគតិយុត្តិ អត្រាពន្ធលើប្រាក់ចំណេញ ពន្ធលើប្រាក់ចំណេញត្រូវបង់ ឥណទានពន្ធ និងហត្ថលេខាទទួលខុសត្រូវរបស់អភិបាល បណ្ណាធិការ ឬកម្មសិទ្ធករសហគ្រាស ។

២- **ទំព័រទី២** : ពត៌មានស្តីពីការចូលរួមមូលធនរបស់ម្ចាស់ភាគហ៊ុន និងពត៌មានអំពីនិយោជិកសហគ្រាសនៅក្នុងការិយបរិច្ឆេទដូចជា អ្នកគ្រប់គ្រងជាអ្នកចូលហ៊ុន អ្នកគ្រប់គ្រងមិនមែនជាអ្នកចូលហ៊ុន និយោជិក-កម្មករ តួនាទីនៅក្នុងក្រុមហ៊ុន និងអត្ថប្រយោជន៍បន្ថែមដែលទទួលបានក្នុងការិយបរិច្ឆេទ ។

៣- **ទំព័រទី៣ និងទី៤**: តារាងតុល្យការ ដែលការបង្ហាញរបាយការណ៍ហិរញ្ញវត្ថុសមស្របតាម **សគគ ១** ។

៤- **ទំព័រទី៥ និងទី៦** : របាយការណ៍លទ្ធផល ដែលការបង្ហាញរបាយការណ៍ហិរញ្ញវត្ថុស្រមស្របតាម **សគគ១** ។

៥- **ទំព័រទី៧** : តារាងគណនាថ្លៃដើមផលិតផលបានលក់ចំពោះសហគ្រាសផលិតកម្ម ។

៦- **ទំព័រទី៨** : តារាងគណនាថ្លៃដើមទំនិញ ឬសេវាបានលក់ចំពោះសហគ្រាសក្រៅពីផលិតកម្ម ។

៧- **ទំព័រទី៩ និងទី១០** : តារាងគណនាពន្ធលើប្រាក់ចំណេញ (តារាងកែតម្រូវក្រៅគណនេយ្យ គឺធ្វើឡើងពីលទ្ធផលគណនេយ្យអោយទៅជាលទ្ធផលសារពើពន្ធ) ។

៨- **ទំព័រទី១១ និងទី១២** : តារាងគណនាវិភាគទានសប្បុរសធម៌ ការប្រាក់អាចកាត់កងបាន និងឥណទានខាតយោងទៅមុខ ។

៩- **ទំព័រទី១៣ និងទី១៤** : តារាងគណនារំលស់តាមច្បាប់ស្តីពីសារពើពន្ធ ។

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខ័ណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨

St 92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA. Phone : 855-23-724 664 Fax : 855-23-427 798

១០- **ទំព័រទី១៥** : តារាងគណនាតំលៃលើស ឬខ្វះពីការលក់ ឬការដកចេញនូវទ្រព្យសកម្មរយៈពេលវែងតាមច្បាប់ស្តីពីស្តីសារពើពន្ធ ។

១១- **ទំព័រទី១៦** : តារាងគណនាសវិធានធន ។

អនុលោមតាមមាត្រា២៩ នៃច្បាប់ស្តីពីសារពើពន្ធ អ្នកជាប់ពន្ធតាមរបបស្វ័យប្រកាស (អ្នកជាប់ពន្ធតាមរបបពិត) ត្រូវដាក់លិខិតប្រកាសពន្ធលើប្រាក់ចំណេញជូនរដ្ឋបាលសារពើពន្ធក្នុងរយៈវេលា ៣ខែ ក្រោយពីដំណាច់ឆ្នាំសារពើពន្ធ ។ សំរាប់ការិយបរិច្ឆេទឆ្នាំ២០០៥ អ្នកជាប់ពន្ធតាមរបបស្វ័យប្រកាស (របបពិត) ត្រូវដាក់លិខិតប្រកាសជូនរដ្ឋបាលសារពើពន្ធយ៉ាងយឺតត្រឹមថ្ងៃទី៣១ ខែមិនា ឆ្នាំ២០០៦ ។

ដើម្បីអោយលោក-លោកស្រីជាគណនេយ្យករសហគ្រាស និងប្រតិបត្តិករវិជ្ជាជីវៈគណនេយ្យ-ពន្ធដារបំរើសេវាកម្មអោយអ្នកជាប់ពន្ធតាមរបបស្វ័យប្រកាស (របបពិត) មានពេលវេលាគ្រប់គ្រាន់ក្នុងការសិក្សាស្វែងយល់ និង រៀបចំបំពេញលិខិតប្រកាសពន្ធលើប្រាក់ចំណេញតាមគំរូថ្មីបានត្រឹមត្រូវ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ សំរេចពន្យាពេលការដាក់លិខិតប្រកាសពន្ធលើប្រាក់ចំណេញតាមគំរូថ្មី សំរាប់ការិយបរិច្ឆេទឆ្នាំ២០០៥ យ៉ាងយឺតបំផុតនៅដំណាច់ខែឧសភា ឆ្នាំ២០០៦ ។

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ សង្ឃឹម និង ជឿជាក់ថា អស់លោក-លោកស្រី មុខជាយកចិត្តទុកដាក់អនុវត្តប្រកាសណែនាំនេះបានល្អ និងត្រឹមត្រូវជាមិនខានឡើយ ។

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

**គាត ឈន់**